PESTECH

# ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក

# របាយការណ៍ប្រចាំត្រីមាស

## ត្រីមាសទី៣ សម្រាប់ឆ្នាំហិរញ្ញវត្ថុ

## ដែលបានបញ្ចប់នៅ

## ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២១

PESTECH

# ទិន្នន័យហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | | ត្រីមាសទី៣ ឆ្នាំ ២០២១ (លានរៀល) | ឆ្នាំ ២០២០ (លានរៀល) |
|---|---|---|---|
| ទ្រព្យសកម្មសរុប | | ១ ០៦២ ២៨២ | ១ ០១៦ ១១២ |
| បំណុលសរុប | | ៩៧៥ ៤៥៦ | ៩៤៦ ១៥៥ |
| មូលធនសរុប | | ៨៦ ៨២៦ | ៦៩ ៩៥៧ |
| **ចំណេញ/ (ខាត)** | | **ត្រីមាសទី៣ ឆ្នាំ ២០២១ (លានរៀល)** | **ត្រីមាសទី៣ ឆ្នាំ ២០២០ (លានរៀល)** |
| ចំណូលសរុប | | ៥២ ៥៦៤ | ៤៨ ៦៦៣ |
| ចំណេញ មុនបង់ពន្ធ | | ៣ ៧១៤ | ៣ ១៦៦ |
| ចំណេញ ក្នុងការិយបរិច្ឆេទ | | ២ ២២០ | ១ ៤៦០ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ៦ ០៣៥ | (៩ ៩៥៧) |
| **អនុបាតហិរញ្ញវត្ថុ** | | **ត្រីមាសទី៣ ឆ្នាំ២០២១** | **ឆ្នាំ២០២០** |
| អនុបាតសាធនភាព | | ០,៨១% | ៧,៤៣% |
| អនុបាតសាធនភាព (កម្ចីទូទៅ)* | | ៥៨,៩៤% | ២០៤,៦១% |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ០,៨៧ | ០,២៨ |
| | អនុបាតចរន្តលឿន | ០,៨៥ | ០,២៤ |
| | | **ត្រីមាសទី៣ ឆ្នាំ២០២១** | **ត្រីមាសទី៣ ឆ្នាំ២០២០** |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | ០,២១% | ០,១៥% |
| | អនុបាតចំណេញធៀបនឹងមូលធន | ២,៥៦% | ១,៩៩% |
| | អនុបាតគម្លាតចំណេញដុល | ២១,១៥% | ៣៣,៨៣% |
| | អនុបាតគម្លាតចំណេញភាព | ៤,២២% | ៣,០០% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធ | ៣០ | ២១ |
| អនុបាតលទ្ធភាពសងការប្រាក់ | | ១.៤២ | ១.៤៧ |
| ភាគលាភក្នុងមួយភាគហ៊ុន (ប្រសិនមាន) (សម្រាប់អង្គភាពដែលបានចុះបញ្ជី) | | - | - |
| អនុបាតចម្បងផ្សេងៗទៀត (ប្រសិនមាន) | | - | - |

* កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមិនរាប់បញ្ចូលក្ខខណ្ឌកម្ចីរយៈពេលវែងដែលបានធានាដោយដំណើរការនៃគម្រោងទូទាត់ពន្យាពេលដែលមានកិច្ចព្រមព្រៀងទូទាត់ដោយផ្ទាល់ជាមួយអគ្គិសនីកម្ពុជា។ កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមានចំនួន ៥ ៨០៥ លានរៀល និងកម្ចីរយៈពេលវែង មានចំនួន ៤១៧ ៩៥៧ លានរៀល។

PESTECH

# សមាសភាពក្រុមប្រឹក្សាភិបាល



**Paul Lim Pay Chuan**
ប្រធានក្រុមប្រឹក្សាភិបាល



**Lim Ah Hock**
អភិបាល



**Han Fatt Juan**
នាយកប្រតិបត្តិ/ប្រធានប្រតិបត្តិ



**Charles Tan Pu Hooi**
អភិបាល



ដាវ អានសាន
អភិបាលឯករាជ្យ

PESTECH

# មតិរបស់ប្រធានក្រុមប្រឹក្សាភិបាល

ជូនចំពោះភាគហ៊ុនិក

ខ្ញុំបាទមានសេចក្តីសោមមនស្សរីករាយជាអនេកក្នុងការបង្ហាញនូវរបាយការណ៍ត្រីមាសទី៣ប្រចាំឆ្នាំ២០២១ របស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក (ហៅកាត់ថា "PLC)។

ក្នុងអំឡុងត្រីមាសទីបី PCL នៅតែបន្តឆ្លងកាត់នឹងឥទ្ធិពលនៃការឆ្លងជម្ងឺរាតត្បាតជាសាកលដែលប៉ះពាល់ដល់ការធ្វើដំណើរជាអន្តរជាតិ និងការដឹកជញ្ជូនជាទូទៅផងដែរ។

ការិយាល័យក្នុងតំបន់របស់យើងខ្ញុំនៅតែបើកដំណើរការ និងខិតខំបន្តសកម្មភាពនៅតាមការដ្ឋានដែលមានភាពលំបាកនៅក្នុងការដឹកជញ្ជូន និងការផ្ញើលិខិតស្នាមផ្សេងៗ។

ចំពោះករណីនេះ ក្រុមប្រឹក្សាភិបាលបានកំពុងត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើស្ថានភាពវិវត្តន៍នៃជម្ងឺកូវីដ ១៩ នៅប្រទេសកម្ពុជា និងចាត់វិធានការការពារជាមុន ក្នុងករណីចាំបាច់ដើម្បីធានានូវសុខមាលភាព និងសុវត្ថិភាពដល់ក្រុមការងារ ក៏ដូចជារក្សានូវកិច្ចប្រឹងប្រែងផ្តល់សេវាកម្មដល់អតិថិជននៅក្នុងប្រទេសកម្ពុជាខាងផ្នែកឧស្សាហកម្មហេដ្ឋារចនាសម្ព័ន្ធថាមពលផងដែរ។

ក្រុមហ៊ុននឹងនៅតែផ្តោតលើចក្ខុវិស័យរបស់ខ្លួនដើម្បីបង្កើតហេដ្ឋារចនាសម្ព័ន្ធថាមពលដែលមានមូលដ្ឋាននៅប្រទេសកម្ពុជាដើម្បីបម្រើសេវាក្នុងតំបន់ឥណ្ឌូចិន។ ក្រៅពីគម្រោងចាំបាច់នៃកម្លាំងរ៉ូលត៍កម្រិតខ្ពស់ និងបន្ថែមលើខ្សែបញ្ជូនថាមពលកម្រិតខ្ពស់ និងគម្រោងអនុស្ថានីយ យើងខ្ញុំបានប្តេជ្ញាដើរតួបំពេញផ្នែកចំណេះដឹង និងការអនុវត្តគម្រោងថាមពលដែលអាចកកើតឡើងវិញក្នុងតំបន់ ជាពិសេសវិស័យឧស្សាហកម្ម និងផ្នែកពាណិជ្ជកម្មសេដ្ឋកិច្ច។

ការអភិវឌ្ឍន៍ដោយឡែក របាយការណ៍នៃក្រុមប្រឹក្សាភិបាលបានលើកឡើងថា ចាប់តាំងពីព្រឹត្តិការណ៍ធ្វើរដ្ឋប្រហារដែលបានកើតឡើងនៅប្រទេសមីយ៉ាន់ម៉ា នាព្រឹក ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ២០២១ ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមានទីតាំងនៅប្រទេសមីយ៉ាន់ម៉ា បានផ្អាកដំណើរការរហូតដល់មានការជូនដំណឹងជាថ្មីនៅពេលខាងមុខ។ យើងខ្ញុំនឹងរក្សាការិយាល័យ និងកម្លាំងបុគ្គលិកមួយចំនួនតូចរហូតដល់ពេលមួយដែលអាចដំណើរការបាន និងមានសុវត្ថិភាពដល់ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់យើងដើម្បីចាប់ផ្តើមជាថ្មីទៀត។ ការផ្អាកដំណើរការនេះនឹងមិនរំពឹងថាជាផលប៉ះពាល់អវិជ្ជមានក្នុងការបំពេញការងាររបស់ក្រុមហ៊ុនឡើយ។

ជារួមយើងខ្ញុំរក្សានូវទស្សនៈនៃការរីកចម្រើនជាវិជ្ជមានរយៈពេលវែងនៅក្នុងតំបន់។ ជាពិសេសនៅប្រទេសកម្ពុជា និងត្រូវបន្តកសាងសមត្ថភាពវិស្វកម្មក្នុងស្រុក និងស្វែងយល់នូវមធ្យោបាយនានាដើម្បីនាំមកនូវសេវាដែលបន្ថែមតម្លៃក្នុងវិស័យសាងហេដ្ឋារចនាសម្ព័ន្ធថាមពលដល់ថ្នាក់ជាតិ និងប្រជាជននៅក្នុងប្រទេសកម្ពុជា និងឥណ្ឌូចិនផងដែរ។

សូមអគុណរ

ព្រះរាជាណាចក្រកម្ពុជា ផេសថិក (ខេមបូឌា) ម.ក PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

LIM PAY CHUAN

ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០២១

PESTECH

# សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ

ភាគហ៊ុនិក ជាទីរាប់អាន

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក (ហៅកាត់ថា "PCL") បានបង្ហាញលទ្ធផលរបាយការណ៍ហិរញ្ញវត្ថុពីត្រីមាសមួយទៅត្រីមាសកាន់តែល្អប្រសើរក្នុងអំឡុងត្រីមាសទីបីប្រចាំ ឆ្នាំ២០២១។

អំឡុងត្រីមាសនេះ PCL បានធ្វើកិច្ចការយ៉ាងមមារញឹកលើគម្រោងរ៉ែមាសអូខ្វាវ ដែលស្ថិតក្នុងខេត្តមណ្ឌលគីរី។ សូមបញ្ជាក់ថាគម្រោងសាងសង់អណ្តូងរ៉ែមាសអូក្វាវនឹងត្រូវបញ្ចប់នៅខែ មេសា ឆ្នាំ ២០២១ ដោយមានការសម្ពោធដើម្បីអនុវត្តបន្តទៀត ។

យើងខ្ញុំក៏កំពុងធ្វើការយ៉ាងសកម្មលើរោងចក្រថាមពលបន្ទះសូឡាខ្នាតធំទំហំ ២០ មេហ្គាវ៉ាត់ ដែលមានទីតាំងនៅ ក្រុងបាវិត ខេត្តស្វាយរៀង ដោយមានការងារស៊ីវិល កំពុងត្រូវបានដំណើរការជាបណ្តើរៗ និងការបញ្ជាទិញសម្ភារៈសំខាន់ៗ ក៏ដូចជាគ្រឿងបន្លាស់ត្រូវបានធ្វើឡើងសម្រាប់ប្រើប្រាស់ក្នុងត្រីមាសទី បួន ឆ្នាំ ២០២១ នេះតទៅ។

មួយវិញទៀត គម្រោងខ្សែបញ្ជូនអគ្គីសនីប្រវែង ១៣០គីឡូម៉ែត្រ នៅភាគខាងកើតនៃខេត្តសៀមរាប និង ឧត្តរមានជ័យ កំពុងតែបន្តដំណើរការជាបន្តបន្ទាប់ ជាមួយការចាក់គ្រឹះដែលកំពុងបន្តធ្វើនៅលើទីតាំងដែលបានកំណត់។ ការដឹកជញ្ជូនសំភារៈផ្សេ ងៗត្រូវបានគេរំពឹងថានឹងអនុវត្តនៅពីរបីត្រីមាសបន្ទាប់ដែលនឹងបន្តសាងសង់ខ្សែបញ្ជូនអគ្គីសនី និងខ្សែចម្លងថាមពលអគ្គីសនី។

PCL ត្រូវបានតម្រូវឱ្យបំពេញការងារផ្នែកខ្លះនៃគម្រោងខ្សែបញ្ជូនថាមពលអគ្គីសនី និង ប្រព័ន្ធចែកចាយដំណាក់កាលទីពីរ(I) ក្នុងកម្លាំង ២៣០ គីឡូវ៉ុល ដែលជាគម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលដ៏សំខាន់មួយនៅក្នុងបេះដូងនៃរាជធានីភ្នំពេញ។ គម្រោងដែលពាក់ព័ន្ធនឹងការដាក់ពង្រាយម៉ាស៊ីន ("HDD") ដែលបង្កលទ្ធភាពរំខានតិចបំផុតដល់ការធ្វើចរាចរ និងការធ្វើដំណើរថ្មើជើង។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំក្នុងការបន្តសកម្មភាពអនុវត្តគម្រោង ទោះស្ថិតក្នុងស្ថានភាពរីករាលដាលនៃការឆ្លងជម្ងឺរាតត្បាតនេះក៏ដោយ ហើយនៅតែខិតខំប្រឹងប្រែងសហការជាមួយអាជ្ញាធរពាក់ព័ន្ធនានា ក្នុងការធានាឱ្យបាននូវមជ្ឈដ្ឋានការងារដែលមានសុវត្ថិភាពសម្រាប់ក្រុមសមាជិកការងារទាំងអស់។

សូមអគុណ

HAN FATT JUAN

**ប្រធាននាយកប្រតិបត្តិ**

ថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០២១

PESTECH

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ....................................................................................................... i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ....................................................................................... ii

សមាសភាពក្រុមប្រឹក្សាភិបាល .................................................................................................. iii

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ................................................................................. iv

សេចក្តីថ្លែងប្រធាននាយកប្រតិបត្តិ .............................................................................................. v

**ផ្នែកទី១៖** ព័ត៌មានទូទៅនៃក្រុមហ៊ុន ចុះបញ្ជី

ក. អត្តសញ្ញាណក្រុមហ៊ុនចុះបញ្ជី

ខ. សកម្មភាពអាជីវកម្ម

គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

**ផ្នែកទី២៖** ព័ត៌មានពីលទ្ធផលប្រតិបត្តិការអាជីវកម្ម

ក. លទ្ធផលប្រតិបត្តិការជីវកម្ម

ខ. រចនាសម្ព័ន្ធចំណូល

**ផ្នែកទី៣៖**របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្រឡើងវិញដោយសវនកងករាជ្យ

**ផ្នែកទី៤៖** កិច្ចពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

ខ. កត្តាសំខាន់ៗដែលជះឥទ្ធិពលលើផលចំណេញ

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងប្រាក់ចំណូល

ឃ. ផលប៉ះពាល់នៃអត្រាប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងតម្លៃទំនិញ

ង. ផលប៉ះពាល់នៃអតិផរណា

ច. សេដ្ឋកិច្ច សារពើពន្ធ គោលនយោបាយរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

**ផ្នែកទី៥៖** ព័ត៌មានសំខាន់ៗដ៏ទៃផ្សេងទៀតសម្រាប់ការការពារវិនិយោគិន

ហត្ថលេខារបស់អភិបាលនៃក្រុមហ៊ុនចុះបញ្ជី

PESTECH

## ផ្នែកទី១៖ ព័ត៌មានទូទៅនៃក្រុមហ៊ុនចុះបញ្ជី

### ក. អត្តសញ្ញាណចុះបញ្ជីឈ្មោះក្រុមហ៊ុនចុះបញ្ជីជាភាសាខ្មែរ៖ **ផេសថិក (ខេមបូឌា) ម.ក**

ជាអក្សរឡាតាំង៖ PESTECH (CAMBODIA) PLC

បទដ្ឋានកូដ៖ **ផ.ថ.ខ**

អាសយដ្ឋាន៖ **ផ្ទះលេខ ០៦ ផ្លូវលេខ ៥៨៨ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

ទូរសព្ទលេខ៖ **+៨៥៥ ២៣ ៨៨២ ១០៥**

ទូរសារ៖ **+៨៥៥ ២៣ ៨៨២ ១០៦**

គេហទំព័រ៖ www.pestech.com.kh

អ៊ីម៉ែល៖ info@pestech.com.my

លេខវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន៖ **០០០០០៩៥៧**

កាលបរិច្ឆេទ៖ **០៥ កុម្ភៈ ២០១០**

លេខអាជ្ញាប័ណ្ណអាជីវកម្ម៖ **៣២៦ ប្រក.ជនស.អសណ**

ចេញដោយ៖ MLMUPC កាលបរិច្ឆេទ៖ **២០ ធ្នូ ២០១៨**

ឯកសារបង្ហាញព័ត៌មានចុះបញ្ជី គ.ម.ក លេខ **១៧១/២០គ.ម.ក/ស.ស.រ**

កាលបរិច្ឆេទ៖ **២២ កក្កដា ២០២០**

អ្នកតំណាងរបស់ក្រុមហ៊ុន៖ Paul Lim Pay Chuan

### ខ. ប្រភេទអាជីវកម្ម

PCL បានរួមចំណែកជាចម្បងក្នុងការផ្តល់ វិស័យវិស្វកម្ម និងដំណោះស្រាយបច្ចេកទេសនៃប្រព័ន្ធអគ្គីសនីដ៏ទូលំទូលាយសម្រាប់៖

- ការរចនាប្លង់ លទ្ធកម្ម សាងសង់ តម្លើង និងការដាក់ឱ្យប្រើប្រាស់អនុស្ថានីយ៍ HV និង EHV ខ្សែបញ្ជូនអគ្គីសនី HV និង EHV ព្រមទាំងប្រព័ន្ធខ្សែកាបអគ្គីសនីក្រោមដីសម្រាប់បញ្ជូន និងចែកចាយអគ្គីសនីផងដែរ
- កិច្ចដំណើរការ និងការថែទាំ ("O&M") ខ្សែបញ្ជូនអគ្គីសនី និងអនុស្ថានីយ៍ និង
- ការធ្វើពាណិជ្ជកម្ម បរិក្ខារប្រព័ន្ធអគ្គីសនី និងឧបករណ៍ ជាកម្មសិទ្ធិ និងមិនមែនជាកម្មសិទ្ធិ

### គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

នៅថ្ងៃទី១២ សីហា ២០២០ PCL បានបញ្ចប់ការបោះផ្សាយមូលបត្រលើកដំបូង និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រគោលនៃគណៈកម្មការមូលត្រកម្ពុជា។

PESTECH

## ផ្នែកទី២៖ ព័ត៌មានអំពីលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម

### ក.លទ្ធផលនៃប្រតិបត្តិការអាជីវកម្មតាមផ្នែក

កិច្ចសន្យាលើ វិស្វកកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់ឱ្យដំណើរការ ("EPCC") ខ្សែបញ្ជូនអគ្គីសនី និងអនុស្ថានីយ៍គឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលសម្រាប់ត្រីមាសដែលមានទឹកប្រាក់ចំនួន ៤៩ ៣៧៨ លានរៀល (ត្រីមាសទីបី ឆ្នាំហិរញ្ញវត្ថុ ២០២០៖ ៤៦ ៣៨៣ លានរៀល) ដែលស្មើនឹងប្រមាណ ៩៣,៩% (ត្រីមាសទីបី នៃឆ្នាំហិរញ្ញវត្ថុ ២០២០៖ ៩៥,៣%) បើប្រៀបធៀបនឹងចំណូលសរុប។

ការបំពេញបន្ថែមលើសេវាកម្ម EPCC របស់យើងដែលជា ប្រតិបត្តិការ និងសេវាថែទាំដែលស្មើនឹងប្រមាណ ៣ ១៨៦ លានរៀល ឬ ៦,១% នៃចំណូលសរុប (ត្រីមាសទីបី នៃឆ្នាំហិរញ្ញវត្ថុ ២០២០៖ ២ ២៨០ លានរៀល ឬ ៤,៧%)។ ការកើនឡើងប្រាក់ចំណូលត្រូវបានទទួលស្គាល់ក្រោមប្រតិបត្តិការ និងសេវាថែទាំ បើប្រៀបធៀបនឹងត្រីមាសដូចគ្នានៃឆ្នាំហិរញ្ញវត្ថុមុន ដែលភាគច្រើនបណ្តាលមកពីការបញ្ចប់ប្រតិបត្តិការនៃគម្រោងនៅក្រុងព្រះសីហនុ នៅខែ មីនា ២០២០។

### ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី៣ ឆ្នាំ២០២១ | | ត្រីមាសទី៣ ឆ្នាំ២០២០ | | បម្រែបម្រួល | |
|---|---|---|---|---|---|---|---|
| | | លានរៀល | ភាគរយ | លានរៀល | ភាគរយ | លានរៀល | ភាគរយ |
| ១ | វិស្វកកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់ឱ្យដំណើរការ ("EPCC") កិច្ចសន្យាសម្រាប់អគ្គីសនី និងអនុស្ថានីយ៍ | ៤៩ ៣៧៨ | ៩៣,៩ | ៤៦ ៣៨៣ | ៩៥,៣ | ២ ៩៩៥ | ៦,៥ |
| ២ | ប្រតិបត្តិការ និងសេវាថែទាំ | ៣ ១៨៦ | ៦,១ | ២ ២៨០ | ៤,៧ | ៩០៦ | ៣៩,៧ |
| | **ប្រាក់ចំណូលសរុប** | **៥២ ៥៦៤** | **១០០,០** | **៤៨ ៦៦៣** | **១០០,០** | **៣ ៩០១** | **៨,០** |

## ផ្នែកទី៣៖ របាយការណ៍ហិរញ្ញវត្ថុពិនិត្យដោយសវនករខាងក្រៅ

សូមយោងទៅតាមរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយត្រូវបានធ្វើការត្រួតពិនិត្រឡើងវិញរួចរាល់ហើយដោយសវនករឯករាជ្យ។

PESTECH

## ផ្នែកទី៤៖ កិច្ចពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង ("MD&A")

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

១. ការវិភាគចំណូល

ចំណូលសរុបសម្រាប់រយៈពេលបីខែ សម្រាប់របាយការណ៍ហិរញ្ញវត្ថុដែលបានបញ្ចប់ថ្ងៃទី៣១ ខែមីនា ២០២១ បានកត់ត្រាត្រឹម ៥២ ៥៦៤ លានរៀលកើនឡើងចំនួន ៣ ៩០១ លានរៀល ឬ ៨,០% បើប្រៀបធៀបនឹងរបាយការណ៍ត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន មានចំនួន ៤៨.៦៦៣ លានរៀល។

សម្រាប់របាយការណ៍ហិរញ្ញវត្ថុរយៈពេល ប្រាំបួន ខែ ក្រោមការត្រួតពិនិត្យឡើងវិញ ចំណូលបានកត់ត្រាចំនួនត្រឹម ១៦២ ៨៦២ លានរៀល កើនឡើងចំនួន ២៧ ៣២២ លានរៀល ឬ ២០,២% បើប្រៀបធៀបទៅនឹងរបាយការណ៍ត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន មានចំនួន ១៣៥.៥៤០ លានរៀល។

ប្រាក់ចំណូលសម្រាប់ត្រីមាសនេះ គឺទទួលបានពីការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធអគ្គីសនីនានានៅក្នុងប្រទេសកម្ពុជា និង Papua New Guinea។

### ២. ការវិភាគចំណូលតាមផ្នែក

ដំណើរការនៃវិស្វកកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់ឱ្យដំណើរការ ("PECC) កិច្ចសន្យាសម្រាប់បណ្តាញអគ្គីសនី និងអនុស្ថានីយ៍គឺជាកត្តាចូលរួមសំខាន់សម្រាប់ផ្តល់នូវចំណូលប្រចាំត្រីមាសមានទឹកប្រាក់ចំនួន ៤៩ ៣៧៨ លានរៀល (ត្រីមាសទីបី នៃឆ្នាំហិរញ្ញវត្ថុ ២០២០៖ ៤៦ ៣៧៣ លានរៀល) ដែលស្មើនឹងប្រមាណ ៩៣,៩% (ត្រីមាសទីបី នៃឆ្នាំហិរញ្ញវត្ថុ ២០២០៖ ៩៥,៣%) ធៀបនឹងចំណូលសរុប។

ការបំពេញបន្ថែមនៃសេវាកម្ម PECC របស់យើងដែលជាប្រតិបត្តិការ និងសេវាថែទាំដែលស្មើរនឹងប្រមាណ ៣ ១៨៦ លានរៀល ឬ ៦,១% នៃចំណូលសរុប (ត្រីមាសទីបី នៃឆ្នាំហិរញ្ញវត្ថុ ២០២០៖ ២ ២៨០ លានរៀល ឬ ៤,៧%)។ ការកើនឡើងប្រាក់ចំណូល ត្រូវបានទទួលស្គាល់ក្រោមប្រតិបត្តិការ និងសេវាថែទាំ បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដែលភាគច្រើនបណ្តាលមកពីការបញ្ចប់ប្រតិបត្តិការនៃគម្រោងនៅក្រុងព្រះសីហនុ នៅខែ មីនា ២០២០។

### ៣. ការវិភាគគម្លាតចំណេញដុល

ចំណេញដុលនៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ បានកត់ត្រាមានចំនួនត្រឹម ២១,១% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដែលមានចំនួន ៣៣,៨ % ដោយថយចុះចំនួន ១២,៧%។ ការកើនឡើងចំណេញដុលក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន គឺភាគច្រើនបណ្តាលមកពីការបញ្ចប់គម្រោងធំទាំងពីរ។ ចំណេញដុលនៃវឌ្ឍនភាពគម្រោងក្នុងត្រីមាសបច្ចុប្បន្នគឺស្ថិតក្នុងការរំពឹងទុករបស់យើងខ្ញុំ។

## ៤. ការវិភាគចំណេញមុនបង់ពន្ធ

ចំណេញមុនបង់ពន្ធនៅត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ បានកត់ត្រាមានចំនួនត្រឹម ៣ ៧១៤ លានរៀល បើប្រៀបធៀបទៅនឹងចំណេញដុលមុនបង់ពន្ធនៅត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដែលមានចំនួន ៣ ១៦៦ លានរៀល ដោយកើនឡើងចំនួន ៥៤៨ លានរៀល ឬ ១៧,៣%។

ចំណេញមុនបង់ពន្ធនៅត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ បានកត់ត្រាមានចំនួនត្រឹម ១ ៨៧០ លានរៀល បើប្រៀបធៀបទៅនឹងចំណេញដុលមុនបង់ពន្ធនៅឆ្នាំហិរញ្ញវត្ថុលើកមុន ដែលមានចំនួន ៣៦ ១៩២ លានរៀល ដោយថយចុះមានចំនួន ៣៤ ៣២២ លានរៀល ឬ ៩៤,៨%។

## ៥. ការវិភាគចំណេញក្នុងការិយបរិច្ឆេទ

លទ្ធផលនៃត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញមានចំនួនត្រឹម ២ ២២០ លានរៀល បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុនមានចំនួន ១ ៤៦០ លានរៀល ដោយកើនឡើងមានចំនួន ៧៦០ លានរៀល ឬ ៥២,១% ។

លទ្ធផលបានបង្ហាញពីការខាតក្រោយពេលបង់ពន្ធសម្រាប់ត្រីមាសបច្ចុប្បន្នមានចំនួន ៧៤១ លានរៀល  បើប្រៀបធៀបទៅនឹងប្រាក់ចំណេញក្នុងការិយបរិច្ឆេទនៅឆ្នាំហិរញ្ញវត្ថុមុន ដែលមានចំនួន ២៨ ៣៤៧ លានរៀល ដោយថយចុះចំនួន ២៩ ០៨៨ លានរៀល ឬ ១០២.៦% ។ ទោះបីជាយ៉ាងណាក៏ដោយប្រៀបធៀបនឹងលទ្ធផលត្រីមាសថ្មីៗកន្លងទៅ លទ្ធផលសរុបសម្រាប់ឆ្នាំហិរញ្ញវត្ថុបច្ចុប្បន្នមានការរីកចម្រើនដែលមានចំនួន ២ ២២៧ លានរៀល ឬ ៧៥% ដែលភាគច្រើនបណ្តាលមកពីការអនុវត្តថ្មីៗនូវគម្រោងដែលមានស្រាប់។

## ខ. កត្តាសារវន្តដែលជះឥទ្ធិពលលើប្រាក់ចំណេញ

អំឡុងពេលក្រោមការត្រួតពិនិត្យឡើងវិញ មិនមានកត្តាសំខាន់ៗណាមួយដែលជះឥទ្ធិពលលើប្រាក់ចំណេញរបស់ប្រតិបត្តិការដល់សម្ព័ន្ធក្រុមហ៊ុនឡើយ។

## គ. ការប្រែប្រួលសំខាន់ៗការលក់ និងប្រាក់ចំណេញ

ចំណូលសរុបសម្រាប់រយៈពេលបីខែនៃឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២១ បានកត់ត្រាមានចំនួន ៥២ ៥៦៤ លានរៀល ដែលតំណាងឱ្យការកើនឡើងចំនួន ៣ ៩០១ លានរៀល ឬ ៨,០% ដោយប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដែលមានចំនួន ៤៨ ៦៦៣ លានរៀល។ សម្រាប់រយៈពេល ប្រាំបួន ខែ ហិរញ្ញវត្ថុក្រោមការត្រួតពិនិត្យឡើងវិញ ចំណូលបានកត់ត្រាមានចំនួន ១៦២ ៨៦២ លានរៀល ដោយកើនឡើងចំនួន ២៧ ៣២២ លានរៀល ឬ ២០,២% ដោយប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដោយមានចំនួន ១៣៥ ៥៤០ លានរៀល។ បម្រែបម្រួលនៃប្រាក់ចំណូលសម្រាប់ត្រីមាសនៃឆ្នាំហិរញ្ញវត្ថុនេះ ភាគច្រើនជាចម្បងបណ្តាលមកពីដំណាក់កាលនៃការអនុវត្តគម្រោងដែលមានស្រាប់។

### ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណបរទេស អត្រាការប្រាក់ និងតម្លៃទំនិញ

ពុំមានផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្តាលមកពីអត្រារូបិយបណ្ណបរទេស អត្រាការប្រាក់ និងការឡើងចុះនៃតម្លៃទំនិញនោះទេ។

### ង. ផលប៉ះពាល់នៃអតិផរណា

ការចំណាយសម្រាប់អាជីវកម្មរបស់យើងគឺដោយសារផលប៉ះពាល់នៃអតិផរណាដែលមានចំនួនប្រហែល ១៥% នៃចំណូលរបស់យើង។ ទោះបីយ៉ាងនេះក្តី អតិផរណានៅក្នុងប្រទេសកម្ពុជា មានចំនួន ៣,១% ( គិតត្រឹម ខែមេសា ឆ្នាំ ២០២១ ប្រភព៖ *មូលនិធិហិរញ្ញវត្ថុអន្តជាតិ៖ អត្រាអតិផរណា តម្លៃអ្នកប្រើប្រាស់គិតជាមធ្យម*) ដែលបង្កផលប៉ះពាល់ចំណេញប្រមាណ ០,៤៧% តែប៉ុណ្ណោះ។ រាល់ចំណាយប្រតិបត្តិការទាំងអស់មានតម្លៃថេរ នៅក្នុងរយៈពេលនៃកិច្ចសន្យាទាំងមូល។ ក្រៅពីការលើកឡើងខាងលើ ពុំមានផលប៉ះពាល់សំខាន់ៗផ្សេងទៀតដែលបណ្តាលមកពីអតិផរណានោះទេ។

### ច. សេដ្ឋកិច្ច សារពើពន្ធ គោលនយោបាយរូបិយវត្ថុរាជរដ្ឋាភិបាល

ពុំមានបម្រែបម្រួលសំខាន់ៗនៅក្នុងគោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ សាច់ប្រាក់របស់រាជរដ្ឋាភិបាល ឬ កត្តានានាដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះលទ្ធផលហិរញ្ញវត្ថុ នៅក្នុងអំឡុងឆ្នាំនេះទេ។

PESTECH

## ផ្នែកទី៥៖ ព័ត៌មានសំខាន់ៗដទៃទៀតសម្រាប់ការការពារវិនិយោគិន

ពុំមានព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន។

PESTECH

**ហត្ថលេខារបស់អភិបាលក្រុមហ៊ុន**

( នឹងត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល ឬយ៉ាងតិចដោយប្រធានប្រតិបត្តិចំនួនពីររូប )

បានអាន និងឯកភាពៈ

ហត្ថលេខា

ឈ្មោះ៖ LIM PAY CHUAN

មុខតំណែង៖ ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី ១០ ខែឧសភា ២០២១